| ២១. | កាត់សក់បុរស (ចាប់ពី ៥កៅអី ឡើងទៅ) | 40 000 | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២២. | អ៊ុតសក់ កាត់សក់ លម្អក្រចក (ចាប់ពី ២កៅអី ទៅ ៤កៅអី) | 40 000 | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២៣. | អ៊ុតសក់ កាត់សក់ លម្អក្រចក (ចាប់ពី ៥កៅអី ឡើងទៅ) | 60 000 | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២៤. | សម្អាងការ (តម្លៃក្រោម ៥០០ដុល្លារអាម៉េរិក) | 100 000 | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២៥. | សម្អាងការ (តម្លៃចាប់ពី ៥០០ដុល្លារអាម៉េរិក ដល់ក្រោម ១ ០០០ដុល្លារអាម៉េរិក) | 200 000 | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| **៣. វិស័យអប់រំ យុវជន និងកីឡា** | | | | | |
| ១. | សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីជាតិ) | 200 000 | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ២. | ការធ្វើសុពលភាពឡើងវិញ | 100 000 | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៣. | សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីអន្តរជាតិ) | 400 000 | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៤. | ការធ្វើសុពលភាពឡើងវិញ | 200 000 | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៥. | ថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗ តិចជាង ១ឆ្នាំ | 200 000 | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៦. | ការធ្វើសុពលភាពឡើងវិញ | 100 000 | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៧. | បង្កើតក្លឹបហាត់ប្រាណ | 200 000 | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៨. | ការធ្វើសុពលភាពឡើងវិញ | 100 000 | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៩. | អាជីវកម្មលក់សម្ភារកីឡា | 200 000 | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១០. | ការធ្វើសុពលភាពឡើងវិញ | 100 000 | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **៤. វិស័យទេសចរណ៍** | | | | | |
| ១. | ផ្ទះសំណាក់ ចាប់ពី ០៨បន្ទប់ ចុះក្រោម (គិតក្នុង ០១បន្ទប់) | 15 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២. | ផ្ទះជួលបន្ទប់ស្នាក់នៅ (គិតក្នុង ០១បន្ទប់) | 5 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៣. | ភោជនីយដ្ឋានទេសចរណ៍ ចាប់ពី ៥០នាក់ ចុះក្រោម | 300 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៤. | អាហារដ្ឋាន | 300 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៥. | តូបលក់អាហារ | 10 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៦. | ហាងលក់គុយទាវ កាហ្វេ | 50 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៧. | ម៉ាស្សា ចាប់ពី ០៥គ្រែ ឬចាប់ពី ០៥កៅអី ចុះក្រោម | 260 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៨. | ខារ៉ាអូខេ ចាប់ពី ០៥បន្ទប់ ចុះក្រោម | 400 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៩. | ស្នូកឃ័រ ចាប់ពី ០៥តុ ចុះក្រោម | 150 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១០. | រថយន្តដឹកទេសចរណ៍ ចំណុះចាប់ពី ០៥កៅអី ចុះក្រោម | 100 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១១. | ម៉ូតូឌុបទេសចរណ៍ | 10 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១២. | ម៉ូតូជួលទេសចរណ៍ | 10 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១៣. | រ៉ឺម៉កម៉ូតូដឹកទេសចរណ៍ | 15 000 | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| **៥. ការងារអត្រានុកូលដ្ឋាន** | | | | | |
| ៥.១. ចំពោះខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ | | | | | |
| ១. | សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២. | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣. | សេចក្តីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ៥.២. ចំពោះរាជធានី ខេត្ត ក្រៅពីខេត្តទាំង ៥ ខាងលើ | | | | | |
| ៤. | សេចក្ដីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៥. | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦. | សេចក្ដីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

## ៦. វិស័យសំណង់

| ល.រ | សេវាកម្ម | តម្លៃសេវា (រៀល) | | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | ក្រៅក្រុង | ក្នុងក្រុង | | | |
| ៦.១. លិខិតអនុញ្ញាតសាងសង់ | | | | | | |
| ភូមិគ្រឹះ | | | | | | |
| ១. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | 420 000 | 600 000 | ២៥ ថ្ងៃ | | |
| ២. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | 560 000 | 800 000 | ២៥ ថ្ងៃ | | |
| ៣. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | 700 000 | 1 000 000 | ២៥ ថ្ងៃ | | |
| ៤. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | 980 000 | 1 400 000 | ២៥ ថ្ងៃ | | |
| ៥. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | 1 260 000 | 1 800 000 | ២៥ ថ្ងៃ | | |
| ផ្ទះល្វែង | | | | | | |
| ៦. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | 280 000 | 400 000 | ២៥ ថ្ងៃ | | |
| ៧. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | 350 000 | 500 000 | ២៥ ថ្ងៃ | | |
| ៨. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | 420 000 | 600 000 | ២៥ ថ្ងៃ | | |
| ៩. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | 560 000 | 800 000 | ២៥ ថ្ងៃ | | |
| ១០. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | 840 000 | 1 200 000 | ២៥ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | ក្រៅក្រុង | ក្នុងក្រុង | | | |
| ថ្មក្រោមឈើលើ | | | | | | |
| ១១. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | 98 000 | 140 000 | ២៥ ថ្ងៃ | | |
| ១២. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | 112 000 | 160 000 | ២៥ ថ្ងៃ | | |
| ១៣. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | 126 000 | 180 000 | ២៥ ថ្ងៃ | | |
| ១៤. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | 140 000 | 200 000 | ២៥ ថ្ងៃ | | |
| ១៥. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | 154 000 | 220 000 | ២៥ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ៦.២. លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល | | | | | |
| ភូមិគ្រឹះ | | | | | |
| ១៦. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ១៧. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ១៨. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ១៩. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២០. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ផ្ទះល្វែង | | | | | |
| ២១. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២២. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២៣. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២៤. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២៥. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ថ្មក្រោមឈើលើ | | | | | |
| ២៦. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២៧. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២៨. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ២៩. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ៣០. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ២០ ថ្ងៃ | | |
| ៦.៣. លិខិតអនុញ្ញាតបើកការដ្ឋាន | | | | | |
| ភូមិគ្រឹះ | | | | | |
| ៣១. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៣២. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៣៣. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៣៤. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៣៥. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ផ្ទះល្វែង | | | | | |
| ៣៦. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៣៧. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៣៨. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៣៩. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤០. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ថ្មក្រោមឈើលើ | | | | | |
| ៤១. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤២. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤៣. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤៤. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤៥. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៦.៤. លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | | | | | |
| ភូមិគ្រឹះ | | | | | |
| ៤៦. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤៧. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤៨. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៤៩. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥០. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ផ្ទះល្វែង | | | | | |
| ៥១. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥២. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥៣. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥៤. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥៥. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ថ្មក្រោមឈើលើ | | | | | |
| ៥៦. | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥៧. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥៨. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៥៩. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៦០. | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៦.៥. សេវាកម្ម ជួសជុល និងសាងសង់របង | | | | | |
| លិខិតអនុញ្ញាត | | | | | |
| ៦១. | ប្រវែងបណ្តោយរបង ចាប់ពី ២០ម៉ែត្រ ចុះក្រោម | 20 000 | ១៥ ថ្ងៃ | | |
| ៦២. | ប្រវែងបណ្តោយរបង លើសពី ២០ម៉ែត្រ ដល់ ២០០ម៉ែត្រ | 40 000 | ១៥ ថ្ងៃ | | |
| ៦៣. | ប្រវែងបណ្តោយរបង លើសពី ២០០ម៉ែត្រ ដល់ ៥០០ម៉ែត្រ | 60 000 | ១៥ ថ្ងៃ | | |
| ៦៤. | ប្រវែងបណ្តោយរបង លើសពី ៥០០ម៉ែត្រ ដល់ ១ ០០០ម៉ែត្រ | 80 000 | ១៥ ថ្ងៃ | | |
| ៦៥. | ប្រវែងបណ្តោយរបង លើសពី ១ ០០០ម៉ែត្រ ដល់ ៥ ០០០ម៉ែត្រ | 100 000 | ១៥ ថ្ងៃ | | |
| ៦៦. | ប្រវែងបណ្តោយរបង លើសពី ៥ ០០០ម៉ែត្រ | 150 000 | ១៥ ថ្ងៃ | | |
| លិខិតបើកការដ្ឋាន | | | | | |
| ៦៧. | ប្រវែងបណ្តោយរបង ចាប់ពី ២០ម៉ែត្រ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៦៨. | ប្រវែងបណ្តោយរបង លើសពី ២០ម៉ែត្រ ដល់ ២០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៦៩. | ប្រវែងបណ្តោយរបង លើសពី ២០០ម៉ែត្រ ដល់ ៥០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៧០. | ប្រវែងបណ្តោយរបង លើសពី ៥០០ម៉ែត្រ ដល់ ១ ០០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ៧១. | ប្រវែងបណ្ដោយរបង លើសពី ១ ០០០ម៉ែត្រ ដល់ ៥ ០០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៧២. | ប្រវែងបណ្ដោយរបង លើសពី ៥ ០០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| លិខិតបិទការដ្ឋាន | | | | | |
| ៧៣. | ប្រវែងបណ្ដោយរបង ចាប់ពី ២០ម៉ែត្រ ចុះក្រោម | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៧៤. | ប្រវែងបណ្ដោយរបង លើសពី ២០ម៉ែត្រ ដល់ ២០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៧៥. | ប្រវែងបណ្ដោយរបង លើសពី ២០០ម៉ែត្រ ដល់ ៥០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៧៦. | ប្រវែងបណ្ដោយរបង លើសពី ៥០០ម៉ែត្រ ដល់ ១ ០០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៧៧. | ប្រវែងបណ្ដោយរបង លើសពី ១ ០០០ម៉ែត្រ ដល់ ៥ ០០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៧៨. | ប្រវែងបណ្ដោយរបង លើសពី ៥ ០០០ម៉ែត្រ | ១០% នៃតម្លៃលិខិតអនុញ្ញាត | ០៧ ថ្ងៃ | | |
| ៦.៦. ការបញ្ជាក់លើការផ្ទេរសិទ្ធិកាន់កាប់ ឬលក់ផ្ដាច់ ឬអំណោយ ឬមរតកអចលនវត្ថុ សម្រាប់បំពេញបែបបទ ចំពោះដី លំនៅស្ថាន ភូមិគ្រឹះ ដែលពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | | | | | |
| ៧៩. | ទំហំដី ក្រោម ១ហិកតា | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 800 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 400 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 100 000 | ១៥ ថ្ងៃ | | ១ លើក |
| ៨០. | ទំហំដី ចាប់ពី ១ហិកតា ដល់ក្រោម ៥ហិកតា | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 1 600 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 800 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 200 000 | ១៥ ថ្ងៃ | | ១ លើក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ៨១. | ទំហំដី ចាប់ពី ៥ហិកតា ឡើងទៅ | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 3 200 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 1 600 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 400 000 | ១៥ ថ្ងៃ | | ១ លើក |
| ៨២. | លំនៅស្ថាន | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 200 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 100 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 50 000 | ១៥ ថ្ងៃ | | ១ លើក |
| ៨៣. | ភូមិគ្រឹះ | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 400 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 200 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 100 000 | ១៥ ថ្ងៃ | | ១ លើក |
| **៧. វិស័យឧស្សាហកម្ម រ៉ែ និងថាមពល** | | | | | |
| ៧.១. សហគ្រាសសិប្បកម្ម | | | | | |
| ១. | កែច្នៃក្រណាត់ ស្បែក កៅស៊ូ ប្លាស្ទិក | 50 000 | ១៥ ថ្ងៃ | ហេតុ | |
| ២. | កែច្នៃស័ង្កសី អាលុយមីញ៉ូម ដែក កញ្ចក់ | 50 000 | ១៥ ថ្ងៃ | ហេតុ | |
| ៣. | កែច្នៃគេនវត្ថុ | 50 000 | ១៥ ថ្ងៃ | ហេតុ | |
| ៤. | ផលិតជើងតាង ពាង លូ ឥដ្ឋការ៉ូ | 50 000 | ១៥ ថ្ងៃ | ហេតុ | |
| ៥. | ធ្វើទៀន ធូប | 50 000 | ១៥ ថ្ងៃ | ហេតុ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ៧.២. ថាមពល | | | | | |
| ៦. | ដំឡើងម៉ាស៊ីនអគ្គិសនីសម្រាប់ធ្វើសេវាកម្មបញ្ចូលអាគុយ ដែលមានកម្លាំងមិនលើសពី ២៥គីឡូវ៉ាត់ (25KW) | 50 000 | ០៥ ថ្ងៃ | ១ ឆ្នាំ | |
| ៧.៣. សេវាកម្ម | | | | | |
| ៧. | ជួសជុលគ្រឿងអគ្គីសនីអេឡិចត្រូនិក | 50 000 | ០៥ ថ្ងៃ | រហូត | |
| ៨. | លាងរថយន្ត ម៉ូតូ | 50 000 | ០៥ ថ្ងៃ | រហូត | |
| ៩. | លាងម៉ូតូ | 40 000 | ០៥ ថ្ងៃ | រហូត | |
| **៨. វិស័យពាណិជ្ជកម្ម** | | | | | |
| ១. | លិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម | 25 000 | ០៧ ថ្ងៃ | ១ ឆ្នាំ | |
| **៩. វិស័យសុខាភិបាល** | | | | | |
| ១. | បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ: | | | | |
| | - ស្នើសុំបើកថ្មី | 200 000 | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| | - បន្តសុពលភាព | 140 000 | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| | - ប្តូរទីតាំង | មិនគិតកម្រៃ | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| ២. | បន្ទប់ព្យាបាលដោយចលនា | | | | |
| | - ស្នើសុំបើកថ្មី | 200 000 | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| | - បន្តសុពលភាព | 140 000 | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| | - ប្តូរទីតាំង | មិនគិតកម្រៃ | ០៧ ថ្ងៃ | ៣ ឆ្នាំ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ៣. | បន្ទប់ថៃទាំងធ្មេញ | | | | |
| | - ស្នើសុំបើកថ្មី | 200 000 | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| | - បន្តសុពលភាព | 140 000 | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| | - ប្តូរទីតាំង | មិនគិតកម្រៃ | ០៧ ថ្ងៃ | ៣ ឆ្នាំ | |
| ៤. | ឱសថស្ថានរង | | | | |
| | - ស្នើសុំបើកឱសថស្ថានរង | 400 000 | ១៥ ថ្ងៃ | ២ ឆ្នាំ | |
| | - បន្តសុពលភាព | 200 000 | ១៥ ថ្ងៃ | ២ ឆ្នាំ | |
| | - ប្តូរទីតាំង | 200 000 | ១៥ ថ្ងៃ | ២ ឆ្នាំ | |
| **១០. វិស័យសាធារណការ និងដឹកជញ្ជូន** | | | | | |
| ១០.១. សេវាកម្ម(ម៉ូតូ) | | | | | |
| ១. | ចុះបញ្ជីថ្មី | 78 000 | ៣០ ថ្ងៃ | អចិន្ត្រៃយ៍ | |
| ២. | ប្តូរប័ណ្ណសម្គាល់(ពណ៌ លេខម៉ាស៊ីន) | 55 000 | ៣០ ថ្ងៃ | អចិន្ត្រៃយ៍ | |
| ៤. | ទុតិយតាប័ណ្ណសម្គាល់ | 60 000 | ៣០ ថ្ងៃ | អចិន្ត្រៃយ៍ | |
| ៦. | តតិយតាប័ណ្ណសម្គាល់ | 65 000 | ៣០ ថ្ងៃ | អចិន្ត្រៃយ៍ | |
| ៣. | ទុតិយតាស្លាកលេខ | 55 000 | ៣០ ថ្ងៃ | អចិន្ត្រៃយ៍ | |
| ៥. | តតិយតាស្លាកលេខ | 60 000 | ៣០ ថ្ងៃ | អចិន្ត្រៃយ៍ | |
| ៧. | ផ្ទេរកម្មសិទ្ធិ | 55 000 | ៣០ ថ្ងៃ | អចិន្ត្រៃយ៍ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ១០.២. ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន | | | | | |
| ៨. | ត្រីចក្រយានយន្ត | 15 000 | ៥ ថ្ងៃ | ១ ឆ្នាំ | |
| ៩. | រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត | 15 000 | ៥ ថ្ងៃ | ១ ឆ្នាំ | |
| ១០.៣. ការបន្តលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន | | | | | |
| ១០. | ត្រីចក្រយានយន្ត | 15 000 | ៥ ថ្ងៃ | ១ ឆ្នាំ | |
| ១១. | រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត | 15 000 | ៥ ថ្ងៃ | ១ ឆ្នាំ | |
| **១១. វិស័យកសិកម្ម** | | | | | |
| ១១.១. លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ជី ថ្នាំ សម្ភារកសិកម្ម | | | | | |
| ១. | ចម្ងាយជិត | 20 000 | ០៧ ថ្ងៃ | ១ ឆ្នាំ | |
| ២. | ចម្ងាយមធ្យម | 25 000 | ០៧ ថ្ងៃ | ១ ឆ្នាំ | |
| ៣. | ចម្ងាយឆ្ងាយ | 35 000 | ០៧ ថ្ងៃ | ១ ឆ្នាំ | |
| ១១.២. វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ | | | | | |
| ៤. | ចម្ងាយជិត | 15 000 | ០២ ថ្ងៃ | ២ ថ្ងៃ | |
| ៥. | ចម្ងាយមធ្យម | 20 000 | ០២ ថ្ងៃ | ២ ថ្ងៃ | |
| ៦. | ចម្ងាយឆ្ងាយ | 30 000 | ០២ ថ្ងៃ | ២ ថ្ងៃ | |

## គ. រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានការិយាល័យច្រកចេញចូលតែមួយ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **១. ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង)** | | | | | |
| ១. | វិញ្ញាបនបត្របញ្ជាក់ការសិក្សា | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២. | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាកំរិត១ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣. | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាកំរិត២ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៤. | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាបឋមភូមិ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៥. | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាទុតិយភូមិ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦. | វិញ្ញាបនបត្របញ្ជាក់ការសិក្សា ថ្នាក់ទី១២ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៧. | វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៨. | វិញ្ញាបនបត្រប្រកបអាជីវកម្ម | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៩. | វិញ្ញាបនបត្រ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១០. | លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត១ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១១. | សញ្ញាបត្រមធ្យមសិក្សាកំរិត ២ (បំពេញវិជ្ជា) | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១២. | សញ្ញាបត្រមធ្យមសិក្សា ទុតិយភូមិ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៣. | សញ្ញាបត្រមធ្យមសិក្សា គរុកោសល្យ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៤. | សញ្ញាបត្រមធ្យមសិក្សា | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ១៥. | សញ្ញាបត្រគ្រូបង្រៀនកំរិតឧត្តម | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៦. | ព្រឹត្តិបត្រលទ្ធផល ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ១៧. | បរិញ្ញាបត្រ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៨. | បរិញ្ញាបត្ររង | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៩. | លិខិតបញ្ជាក់ការសិក្សា | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២០. | អត្តសញ្ញាណប័ណ្ណ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២១. | សៀវភៅស្នាក់នៅ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ២២. | ប័ណ្ណសម្គាល់យានយន្ត | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២៣. | ព្រឹត្តិបត្រពិន្ទុ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ២៤. | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកំរិត២ ចំណេះដឹងទូទៅ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២៥. | វិញ្ញាបនបត្របណ្តោះអាសន្នថ្នាក់បរិញ្ញាបត្រ | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២៦. | វិញ្ញាបនបត្របណ្តោះអាសន្នថ្នាក់បរិញ្ញាបត្ររង | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| **២. ភារធារអត្រានុកូលដ្ឋាន** | | | | | |
| ២.១. ចំពោះខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ | | | | | |
| ១. | សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២. | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣. | សេចក្តីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ២.២. ចំពោះរាជធានី ខេត្ត ក្រៅពីខេត្តទាំង ៥ខាងលើ | | | | | |
| ៤. | សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៥. | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦. | សេចក្តីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| **៣. ការបញ្ជាក់លើការផ្ទេរសិទ្ធិកាន់កាប់ ឬលក់ផ្តាច់ ឬអំណោយ ឬមរតកអចលនវត្ថុ សម្រាប់បំពេញបែបបទ ចំពោះដី លំនៅស្ថាន ភូមិគ្រឹះ ដែលពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ** | | | | | |
| ១. | ទំហំដី ក្រោម ១ហិកតា | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 800 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 400 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 100 000 | ១៥ ថ្ងៃ | | ១ លើក |
| ២. | ទំហំដី ចាប់ពី ១ហិកតា ដល់ក្រោម ៥ ហិកតា | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 1 600 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 800 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 200 000 | ១៥ ថ្ងៃ | | ១ លើក |
| ៣. | ទំហំដី ចាប់ពី ៥ហិកតា ឡើងទៅ | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 3 200 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 1 600 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 400 000 | ១៥ ថ្ងៃ | | ១ លើក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ៤. | លំនៅស្ថាន | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 200 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 100 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 50 000 | ១៥ ថ្ងៃ | | ១ លើក |
| ៥. | ភូមិគ្រឹះ | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 400 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 200 000 | ១៥ ថ្ងៃ | | ១ លើក |
| | - ដីក្រៅក្រុង ឬជនបទ | 100 000 | ១៥ ថ្ងៃ | | ១ លើក |

## ឃ. រដ្ឋបាលឃុំ សង្កាត់

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **១. ការងារអត្រានុកូលដ្ឋាន** | | | | | |
| ១.១. ចំពោះឃុំ សង្កាត់ក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ | | | | | |
| ១. | សំបុត្រកំណើត | មិនយកថ្លៃ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២. | សំបុត្របញ្ជាក់កំណើត( បិទតែមប្រើលើពាក្យសុំ ) | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣. | សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៤. | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍( បិទតែមប្រើលើពាក្យសុំ ) | 2 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៥. | សំបុត្រអាពាហ៍ពិពាហ៍( ពលរដ្ឋខ្មែរ ជាមួយពលរដ្ឋខ្មែរ ) | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦. | សំបុត្រអាពាហ៍ពិពាហ៍( ជនបរទេស ជាមួយពលរដ្ឋខ្មែរ ) | 15 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៧. | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៨. | សំបុត្រមរណភាព( ក្នុងរយៈពេល ១៥ថ្ងៃ ) | មិនយកថ្លៃ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៩. | សំបុត្រមរណភាព( ហួសរយៈពេល ១៥ថ្ងៃ ក្នុងឆ្នាំ ) | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១០. | សេចក្តីចម្លងសំបុត្រមរណភាព | 1 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១.២. ចំពោះឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ក្រៅពីខេត្តទាំង៥ ខាងលើ | | | | | |
| ១១. | សំបុត្រកំណើត | មិនយកថ្លៃ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១២. | សំបុត្របញ្ជាក់កំណើត( បិទតែមប្រើលើពាក្យសុំ ) | 10 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៣. | សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៤. | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍( បិទតែមប្រើលើពាក្យសុំ ) | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៥. | សំបុត្រអាពាហ៍ពិពាហ៍( ពលរដ្ឋខ្មែរ ជាមួយពលរដ្ឋខ្មែរ ) | 15 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ១៦. | សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេស ជាមួយពលរដ្ឋខ្មែរ ) | 30 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៧. | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៨. | សំបុត្រមរណភាព(ក្នុងរយៈពេល ១៥ថ្ងៃ ) | មិនយកថ្លៃ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៩. | សំបុត្រមរណភាព(ហួសរយៈពេល ១៥ថ្ងៃ ក្នុងឆ្នាំ ) | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២០. | សេចក្ដីចម្លងសំបុត្រមរណភាព | 2 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| **២. ការចេញលិខិតអនុញ្ញាត** | | | | | |
| ១.១. ចំពោះឃុំ សង្កាត់ក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ | | | | | |
| ១. | លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ | 5 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ២. | លិខិតបញ្ជាក់ទីលំនៅ | 3 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ៣. | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | 3 000 | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ ច្បាប់ |
| ៤. | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | 10 000 | ៧ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៥. | លិខិតបញ្ជាក់ទាយាទ | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦. | លិខិតបញ្ជាក់កិរិយាមាយាទ | 3 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ៧. | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | 3 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ៨. | លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ( គិតក្នុង ០១ក្បាល) | 2 000 | ៣ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ៩. | លិខិតបញ្ជាក់តបណ្ដាញអគ្គិសនី | 3 000 | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ១០. | លិខិតបញ្ជាក់តបណ្ដាញទឹកស្អាត | 3 000 | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ១១. | លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ | 7 000 | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ សន្លឹក |
| ១២. | លិខិតផ្ទះជួលបន្ទប់ស្នាក់នៅ | 4 000 | ៧ ថ្ងៃ | ២ឆ្នាំ | ១ ច្បាប់ |
| ១៣. | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) | 3 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ១.២. ចំពោះឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ក្រៅពីខេត្តទាំង៥ ខាងលើ | | | | | |
| ១៤. | លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ | 10 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ១៥. | លិខិតបញ្ជាក់ទីលំនៅ | 4 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ១៦. | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | 4 000 | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ ច្បាប់ |
| ១៧. | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | 20 000 | ៧ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ១៨. | លិខិតបញ្ជាក់ទាយាទ | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៩. | លិខិតបញ្ជាក់កិរិយាមាយាទ | 5 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ២០. | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | 5 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ២១. | លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ(គិតក្នុង ០១ក្បាល) | 3 000 | ៣ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ២២. | លិខិតបញ្ជាក់តបណ្ដាញអគ្គិសនី | 5 000 | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ២៣. | លិខិតបញ្ជាក់តបណ្ដាញទឹកស្អាត | 5 000 | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ២៤. | លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ | 10 000 | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ សន្លឹក |
| ២៥. | លិខិតផ្ទះជួលបន្ទប់ស្នាក់នៅ | 5 000 | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២៦. | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |

បញ្ជាក់ ៖ ចំពោះតម្លៃសេវាដែលបានកំណត់ខាងលើនេះ មិនទាន់គិតបញ្ចូលថ្លៃតែមប្រិ៍សារពើពន្ធនៅឡើយ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២១៥អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងសេចក្តីសម្រេចលេខ១២សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងធានានូវការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់គោលការណ៍ យន្តការ បែបបទ នីតិវិធី ប្រភេទសេវា រយៈពេល និងកម្រៃនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## គោលការណ៍នៃការផ្តល់សេវារដ្ឋបាល

**មាត្រា ៤.-**

ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្អែកលើគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាឲ្យបាននូវតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព សមធម៌ និរន្តរភាព និងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជននានា។

**មាត្រា ៥.-**

វិធាន បែបបទ នីតិវិធីនៃការផ្តល់សេវា និងកម្រៃសេវាត្រូវអនុវត្តទៅតាមការកំណត់នៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦.-**

ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលជារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័ននានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

**មាត្រា ៧.-**

ការផ្តល់សេវារដ្ឋបាល និងការយកកម្រៃលើការផ្តល់សេវារដ្ឋបាល ដែលពុំស្របតាមវិធាន បែបបទ នីតិវិធីនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ចាត់ទុកជាអំពើខុសច្បាប់។

## ជំពូកទី៣

## យន្តការនៃការផ្តល់សេវារដ្ឋបាល

**មាត្រា ៨.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំឲ្យមានយន្តការនៃការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ និងធុរជន ស្របតាមគោលការណ៍នៃការផ្តល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

**មាត្រា ៩.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានយន្តការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយត្រូវបន្តអនុវត្តតាមយន្តការនេះ។

**មាត្រា ១០.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដែលពុំទាន់មានយន្តការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំឲ្យមានយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការផ្តល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)។

## ជំពូកទី៤

## ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្ដល់សេវា និងសុពលភាពនៃសេវារដ្ឋបាល

**មាត្រា ១១.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ដល់សេវារដ្ឋបាលរបស់ខ្លួន តាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្ដល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១២.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ដល់សេវារដ្ឋបាលដែលទទួលបានប្រតិភូកម្មពីក្រសួង ស្ថាប័ននានា តាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្ដល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមីនីមួយៗ។

អភិបាលរាជធានី ខេត្ត ត្រូវបានទទួលអំណាចប្រតិភូកម្មក្នុងនាមរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមីក្នុងការចុះហត្ថលេខាសម្រេចលើការផ្ដល់សេវារដ្ឋបាលដែលស្ថិតក្នុងសមត្ថកិច្ចរបស់មន្ទីរ អង្គភាពនានាដូចដែលបានកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

ក្រសួង ស្ថាប័ននានាត្រូវបន្តបែងចែកសមត្ថកិច្ចសម្រេចក្នុងការផ្ដល់សេវារដ្ឋបាលទៅឲ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កិតសេវារដ្ឋបាលឲ្យទៅជិតអ្នកប្រើប្រាស់សេវា។

ក្នុងការអនុវត្តអំណាចប្រតិភូកម្មពីក្រសួង ស្ថាប័ននានា មន្ទីរ អង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត ត្រូវធ្វើជាសេនាធិការជូនអភិបាលរាជធានី ខេត្តលើការងារនេះ។

ការបង់កម្រៃសេវារដ្ឋបាលដែលជារបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើឡើងនៅសាលារាជធានី ខេត្ត។

ក្នុងករណីចាំបាច់ គ.ជ.អ.ប ត្រូវ ធ្វើការសម្របសម្រួលនៅក្នុងការបែងចែកសមត្ថកិច្ចនេះ។

**មាត្រា ១៣.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមានយន្តការផ្ដល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយត្រូវបន្តផ្ដល់នូវប្រភេទសេវារដ្ឋបាលដែលបានធ្វើប្រតិភូកម្មដោយក្រសួង ស្ថាប័ននានារួចហើយ។ កម្រៃសេវា រយៈពេលនៃការផ្ដល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

**មាត្រា ១៤.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមិនទាន់មានយន្តការផ្ដល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ ត្រូវបានអនុញ្ញាតឲ្យផ្ដល់សេវារដ្ឋបាល តាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្ដល់សេវា និងសុពលភាពនៃសេវារដ្ឋបាលស្របតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមីនីមួយៗ ដូចរដ្ឋបាលក្រុង ស្រុកដែលមានការិយាល័យច្រកចេញចូលតែមួយដែរ។

ក្រសួង ស្ថាប័ននានាត្រូវបន្តធ្វើប្រតិភូកម្មការផ្ដល់សេវារដ្ឋបាលទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្កិតសេវារដ្ឋបាលឲ្យទៅជិតអ្នកប្រើប្រាស់សេវា។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបានទទួលអំណាចប្រតិភូកម្មក្នុងនាមរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី

ក្នុងការចុះហត្ថលេខាសម្រេចលើការផ្តល់សេវារដ្ឋបាល ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនេះ។

ការិយាល័យ ឬនិងមន្ទីរ អង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាសេនាធិការជូនអភិបាលក្រុង ស្រុក ខណ្ឌលើការងារនេះ។

ក្នុងករណីចាំបាច់ គ.ជ.អ.ប ត្រូវ ធ្វើការសម្របសម្រួលនៅក្នុងការបែងចែកសមត្ថកិច្ចនេះ។

**មាត្រា ១៥.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានអនុញ្ញាតឲ្យផ្តល់សេវារដ្ឋបាលរបស់ខ្លួន តាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការបង់កម្រៃសេវាដែលជារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងនៅសាលាក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៦.-**

រដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់សេវារដ្ឋបាលតាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលពាក់ព័ន្ធនឹងសេវាអត្រានុកូលដ្ឋាន និងលិខិតអនុញ្ញាតមួយចំនួនដែលមិនមែនជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អាចស្នើធ្វើការកែសម្រួល បំពេញបន្ថែមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលបានកំណត់រួច បន្ទាប់ពីមានការសម្រេចរបស់ក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលរបស់ខ្លួន។

សំណើខាងលើនេះត្រូវសម្រេចដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៨.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបិទផ្សាយជាសាធារណៈនូវតារាងប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលនៅកន្លែងផ្តល់សេវារដ្ឋបាលលើក្តារព័ត៌មានរបស់ថ្នាក់រដ្ឋបាលនីមួយៗ និងតាមមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត។

**មាត្រា ១៩.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប អាចដាក់ចេញនូវសេចក្តីណែនាំអំពីវិធាន បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យការផ្តល់សេវារដ្ឋបាលនានាកាន់តែមានប្រសិទ្ធភាព។

## ជំពូកទី៥

## ការគ្រប់គ្រង និងការចាត់ចែងចំណូលដែលបានមកពីការផ្តល់សេវារដ្ឋបាល

**មាត្រា ២០.-**

រាល់ការប្រមូលកម្រៃសេវារដ្ឋបាលនានា មន្ត្រីទទួលបន្ទុកផ្តល់សេវារដ្ឋបាលត្រូវមានបង្កាន់ដៃប្រគល់ទទួលប្រាក់ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អង្គភាពផ្តល់សេវារដ្ឋបាលត្រូវរក្សាទុកគល់បញ្ជី បង្កាន់ដៃទទួលប្រាក់តាមខែ និងតាមឆ្នាំនីមួយៗក្នុងអង្គភាពរបស់ខ្លួនតាមគោលការណ៍កំណត់។

**មាត្រា ២១.-**

ចំណូលដែលទទួលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ ត្រូវបង់ចូលថវិកាថ្នាក់ជាតិ ឬនិងថវិកាថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។

ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបំពេញការងារនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២២.-**

ប្រាក់រង្វាន់លើកទឹកចិត្តដែលបានមកពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញខ្សែបណ្តោយនានា និងប្រាក់រង្វាន់លើកទឹកចិត្តពីកម្រៃនៃការផ្តល់សេវារដ្ឋបាលដែលបានធ្វើប្រតិភូកម្ម ត្រូវធ្វើការបែងចែកដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សម្រាប់លើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប។

## ជំពូកទី៦

## យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា ២៣.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំបង្កើតឲ្យមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅថ្នាក់រដ្ឋបាលរបស់ខ្លួន។

ក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំអំពីបែបបទ និងនីតិវិធីនៃការរៀបចំបង្កើតប្រព័ន្ធនេះ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ២៤.-**

ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រិសារពេីពន្ធ។

ថ្លៃជាវក្រដាសអគ្រានុកូលដ្ឋាន និងកម្រៃសេវាលើការចុះបញ្ជីអគ្រានុកូលដ្ឋានត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា ២៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*